ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តពោធិ៍សាត់**

សំណុំរឿងរដ្ឋប្បវេណីលេខ ៧៧

ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

សាលក្រមលេខ ១៤៦ (ច)

ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣

**សាលក្រមរដ្ឋប្បវេណី**

**ក្នុងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តពោធិ៍សាត់**

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅវេលាម៉ោង១០ និង០០នាទី ព្រឹក ថ្ងៃសុក្រ ០១កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣ លើសំណុំរឿងរដ្ឋប្បវេណីលេខ ៧៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ជាចៅក្រម នៃសាលាដំបូងខេត្តពោធិ៍សាត់

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តពោធិ៍សាត់

**ដើមចោទ**

ឈ្មោះ [redacted] **សុវចនា** ភេទប្រុស ជនជាតិខ្មែរ មានតួនាទីជា ប្រធាននាយកប្រតិបត្តិ ជាអ្នកតំណាង [redacted] អាសយដ្ឋាននៅអាគារលេខ [redacted]

**អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ**

លោកមេធាវី [redacted]

**សហចុងចម្លើយ**

១. ឈ្មោះ [redacted] **ចាន់ណារិន** ភេទប្រុស កើតថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៨៧ ជនជាតិខ្មែរ អត្តសញ្ញាណប័ណ្ណ សញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៤។

២. ឈ្មោះ [redacted] **វីរ៉ាន់** ភេទស្រី កើតថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៦០ ជនជាតិខ្មែរ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ [redacted] ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ មានអាសយដ្ឋានភូមិ [redacted]។



Scanned with CamScanner

**អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយឈ្មោះ [redacted] រីវ៉ាន់**

លោកមេធាវី [redacted] អត្តលេខ [redacted] ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងជាមេធាវីនៃ [redacted] មាន [redacted]។

**អង្គហេតុ និងចំណុចវិវាទ**

**ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

ស្នើសុំឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារដូចខាងក្រោម៖

**១. បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ដើម**

បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ដើមទៅឱ្យដើមចោទសរុបចំនួន USD ១០.៥៨៣.១៨៨,៤៥ (ដប់លាន ប្រាំរយប៉ែតសិបបីពាន់ មួយរយប៉ែតសិបប្រាំបី ដុល្លារអាមេរិក ក្បៀសសែសិបប្រាំសេន) ឱ្យមកដើមចោទ។

**២. បង្គាប់ឱ្យសហចុងចម្លើយបង់ការប្រាក់**

**ក. ចំពោះឥណទានអាជីវកម្ម** (Fixed Loan) ក្នុងអត្រាការប្រាក់ ៨,៥០% (ប្រាំបីក្បៀសហាសិបភាគរយ) ក្នុង០១ឆ្នាំ លើប្រាក់ដើមចំនួន USD ៨.៥៣៨.៥៤៨,៩១ (ប្រាំបីលាន ប្រាំរយសាមសិបប្រាំបីពាន់ ប្រាំរយ សែសិបប្រាំបី ដុល្លារអាមេរិក ក្បៀសកៅសិបមួយសេន) គិតចាប់ពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ និងក្នុងអត្រាការប្រាក់ ១៨% (ដប់ប្រាំបីភាគរយ) ក្នុង០១ឆ្នាំ លើប្រាក់ដើមចំនួន USD ៨.៥៣៨.៥៤៨,៩១ (ប្រាំបីលាន ប្រាំរយសាមសិបប្រាំបីពាន់ ប្រាំរយសែសិបប្រាំបី ដុល្លារអាមេរិក ក្បៀសកៅសិបមួយសេន) គិតចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់សងគ្រប់ចំនួន។

**ខ. ចំពោះឥណទានវិបារូបន៍** (Overdraft Loan) ក្នុងអត្រាការប្រាក់ ៨,៧៥% (ប្រាំបីក្បៀសចិតសិបប្រាំ ភាគរយ) ក្នុង០១ឆ្នាំ លើប្រាក់ដើមចំនួន USD ២.០៤៤.៦៣៩,៥៤ (ពីរលានសែសិបបួនពាន់ប្រាំមួយរយ សាមសិបប្រាំបួន ដុល្លារអាមេរិក ក្បៀសហាសិបបួនសេន) គិតចាប់ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ និងក្នុងអត្រាការប្រាក់ ១៨% (ដប់ប្រាំបីភាគរយ) ក្នុង០១ឆ្នាំ លើប្រាក់ដើមចំនួន USD ២.០៤៤.៦៣៩,៥៤ (ពីរលានសែសិបបួនពាន់ប្រាំមួយរយសាមសិបប្រាំបួន ដុល្លារអាមេរិក ក្បៀសហាសិបបួនសេន) គិតចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់សងគ្រប់ចំនួន។

**៣. បង្គាប់ឱ្យសហចុងចម្លើយបង់ការប្រាក់ពិន័យ**

**ក. ចំពោះឥណទានអាជីវកម្ម** (Fixed Loan) ក្នុងអត្រាការប្រាក់ ២៤% (ម្ភៃបួនភាគរយ) ក្នុង០១ឆ្នាំ លើប្រាក់ដើមចំនួន USD ៨.៥៣៨.៥៤៨,៩១ (ប្រាំបីលានប្រាំរយសាមសិបប្រាំបីពាន់ប្រាំរយសែសិបប្រាំបី ដុល្លារអាមេរិក ក្បៀសកៅសិបមួយសេន) និងការប្រាក់ដែលខកខានមិនបានបង់ គិតចាប់ពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់សងគ្រប់ចំនួន។



Scanned with CamScanner

៣. ចំពោះឥណទានវិបារូបន៍ (Overdraft Loan) ក្នុងអត្រាការប្រាក់ ២៤% (ម្ភៃបួនភាគរយ) ក្នុង ០១ឆ្នាំ លើប្រាក់ដើមចំនួន USD ២.០៤៤.៦៣៩,៥៤ (ពីរលាន សែសិបបួនពាន់ ប្រាំមួយរយសាមសិបប្រាំបួន ដុល្លារអា-មេរិក ហាសិបបួនសេន) និងការប្រាក់ដែលខកខានមិនបានបង់ គិតចាប់ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ ២០២៣ រហូតដល់ថ្ងៃទូទាត់សងគ្រប់ចំនួន។

៤. បង្គាប់ឱ្យសហចុងចម្លើយបង់ថ្លៃសេវាកម្មច្បាប់ផ្នែកច្បាប់ សំណងការខូចខាត និងការខាតបង់ពេលវេលា ចំនួន USD ១៥០.០០០ (មួយរយហាសិបពាន់ ដុល្លារអាមេរិក)។

៥. ប្រាក់ពន្ធ ប្រាក់ប្រដាប់ក្ដី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់សហចុងចម្លើយ។

៦. ស្នើសុំប្រកាសអនុវត្តសាលក្រមនេះជាបណ្ដោះអាសន្នត្រង់ចំនុចទី១ ទី២ ទី៣ និងទី៤។

**ខ. ដំណើររឿងក្ដី និងចំណុចវិវាទ**

**១. អង្គហេតុនៃដំណើររឿង**

នៅក្នុងរឿងក្ដីនេះ ដើមចោទបានអះអាងថា កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ សហចុងចម្លើយឈ្មោះ [redacted] ចាន់ណារិន និងឈ្មោះ [redacted] រីវ៉ាន់ បានចុះកិច្ចសន្យាខ្ចីបរិភោគជាមួយ ធនាគារ [redacted] ដោយទទួលបានកម្ចីជាប្រាក់ដើមសរុបចំនួន USD ១០.៧០០.០០០ (ដប់លានប្រាំពីររយពាន់ដុល្លារអាមេរិក)។ ក្រោយពីទទួលបានប្រាក់កម្ចីពីធនាគារ [redacted] សហចុងចម្លើយបានទូទាត់សងប្រាក់ត្រឡប់មកធនាគារវិញបានតែមួយរយៈពេលខ្លីតែប៉ុណ្ណោះ ហើយក៏ខកខានមិនបានបង់ប្រាក់មកធនាគារជាបន្តបន្ទាប់ចាប់តាំងពីបានទទួលឥណទានមក។

ក្នុងអនុវត្តកាតព្វកិច្ចរបស់សហចុងចម្លើយ មិនបានគោរពកាតព្វកិច្ចនៃការបង់ប្រាក់តាមកិច្ចសន្យាឡើយ ដោយបានខកខានមិនបានបង់ការប្រាក់ និងប្រាក់ដើមអស់ជាច្រើនខែ ទោះបីជាមានការដាស់តឿនក្រើនរំលឹកជាច្រើនលើកច្រើនសាររួចមកហើយក៏សហចុងចម្លើយនៅតែមិនព្រមចូលខ្លួនមកដោះស្រាយ ក៏ដូចជាការអញ្ជើញនិងជួបដោះស្រាយជាច្រើនលើកច្រើនសារជាមួយសហចុងចម្លើយ ធនាគារ [redacted] ឃើញថាសហចុងចម្លើយពិតជាមិនមានឆន្ទៈ និងគ្មានលទ្ធភាពដើម្បីអនុវត្តកាតព្វកិច្ចរបស់ខ្លួន ក្នុងការបង់សងប្រាក់ដើម និងការប្រាក់។ ការបំពានលក្ខខណ្ឌនៃកិច្ចសន្យានេះ បានបញ្ជាក់ពីការអស់លទ្ធភាព ការគ្មានឆន្ទៈ និងចេតនាគេចវេសពីការទូទាត់សងប្រាក់មកធនាគារ [redacted] យ៉ាងពិតប្រាកដ។ យោងតាមរបាយការណ៍ស្ដីពីបំណុលចុងក្រោយរបស់ធនាគារ [redacted] បំណុលរបស់ឈ្មោះ [redacted] ចាន់ណារិន និងឈ្មោះ [redacted] រីវ៉ាន់ នៅជំពាក់ប្រាក់ដើមចំនួន USD ១០.៥៨៣.១៨៨,៤៥ (ដប់លានប្រាំរយប៉ែតសិបបីពាន់ មួយរយប៉ែតសិបប្រាំបី ដុល្លារអាមេរិក សែសិបប្រាំសេន)។ ហេតុដូចនេះដើមចោទទាមទារឱ្យសហចុងចម្លើយសងប្រាក់ដើមសរុបចំនួន USD ១០.៥៨៣.១៨៨,៤៥ (ដប់លានប្រាំរយប៉ែតសិបបីពាន់ មួយរយប៉ែតសិបប្រាំបី ដុល្លារអាមេរិក សែសិបប្រាំសេន) ដោយផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ រវាងដើមចោទ និងសហចុងចម្លើយ។



Scanned with CamScanner

ផ្អែកតាមកិច្ចសន្យាខ្ចីបរិភោគនេះ ដើមចោទបានទាមទារឱ្យសហចុងចម្លើយសងការប្រាក់ ទៅតាមឥណទានពីរប្រភេទ។ ១. ឥណទានអាជីវកម្ម (Fixed Loan) ក្នុងអត្រាការប្រាក់ ៨,៥០% (ប្រាំបីក្បៀសហាសិបភាគរយ) ក្នុង០១ឆ្នាំ គិតចាប់ពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ និងក្នុងអត្រាការប្រាក់ ១៨% (ដប់ប្រាំបីភាគរយ) ក្នុង០១ឆ្នាំ គិតចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់សងគ្រប់ចំនួន លើប្រាក់ដើមចំនួន USD ៨.៥៣៨.៥៤៨,៩១ (ប្រាំបីលាន ប្រាំរយសាមសិបប្រាំបីពាន់ ប្រាំរយសែសិបប្រាំបី ដុល្លារអាមេរិក ក្បៀសកៅសិបមួយសេន)។ ២. ឥណទានវិបារូបន៍ (Overdraft Loan) ក្នុងអត្រាការប្រាក់ ៨,៧៥% (ប្រាំបីក្បៀសចិតសិបប្រាំ ភាគរយ) ក្នុង០១ឆ្នាំ គិតចាប់ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ និងក្នុងអត្រាការប្រាក់ ១៨% (ដប់ប្រាំបីភាគរយ) ក្នុង០១ឆ្នាំ គិតចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់សងគ្រប់ចំនួន លើប្រាក់ដើមចំនួន USD ២.០៤៤.៦៣៩,៥៤ (ពីរលានសែសិបបួនពាន់ប្រាំមួយរយសាមសិបប្រាំបួន ដុល្លារអាមេរិក ក្បៀសហាសិបបួនសេន)។ ទន្ទឹមនឹងនោះ ដើមចោទបានទាមទារប្រាក់ពិន័យ និងការប្រាក់ដែលខកខានមិនបានបង់ ក្នុងអត្រាការប្រាក់ ២៤% (ម្ភៃបួនភាគរយ) ក្នុង០១ឆ្នាំ គិតចាប់ពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់សងគ្រប់ចំនួន ចំពោះ**ឥណទានអាជីវកម្ម (Fixed Loan)** លើប្រាក់ដើមចំនួន USD ៨.៥៣៨.៥៤៨,៩១ (ប្រាំបីលានប្រាំរយសាមសិបប្រាំបីពាន់ប្រាំរយសែសិបប្រាំបី ដុល្លារអាមេរិក ក្បៀសកៅសិបមួយសេន) និងក្នុងអត្រាការប្រាក់ ២៤% (ម្ភៃបួនភាគរយ) ក្នុង០១ឆ្នាំ គិតចាប់ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់សងគ្រប់ចំនួន ចំពោះ**ឥណទានវិបារូបន៍ (Overdraft Loan)** លើប្រាក់ដើមចំនួន USD ២.០៤៤.៦៣៩,៥៤ (ពីរលាន សែសិបបួនពាន់ ប្រាំមួយរយសាមសិបប្រាំបួន ដុល្លារអាមេរិក ក្បៀសហាសិបបួនសេន)។

ការខកខានមិនបានសងបំណុលតាមការកំណត់ ក្នុងតារាងកាលវិភាគសងប្រាក់នៃកិច្ចសន្យាខ្ចីបរិភោគ ដែលធ្វើឡើងនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ គឺជាការបំពានកាតព្វកិច្ច ដែលមានចែងនៅក្នុងកិច្ចសន្យាខ្ចីបរិភោគ។ ដូចនេះធនាគារមានសិទ្ធិគ្រប់គ្រាន់សុំឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យសហចុងចម្លើយដែលជំពាក់រួមមានប្រាក់ដើម ការប្រាក់ ការប្រាក់ពិន័យ និងថ្លៃចំណាយ សំណងជម្ងឺចិត្ត ការខូចខាតពេលវេលា ថ្លៃសេវាកម្មច្បាប់ជាដើម និងសុំអនុវត្តជាបណ្ដោះអាសន្នលើបំណុលខាងលើនេះ។

លើសពីនេះ ដើមចោទទាមទារឲ្យសហចុងចម្លើយបង់ថ្លៃសេវាកម្មច្បាប់ផ្នែកច្បាប់ សំណងការខូចខាត និងការខាតបង់ពេលវេលា ចំនួន USD ១៥០.០០០ (មួយរយហាសិបពាន់ ដុល្លារអាមេរិក)។

**២. ចំណុចវិវាទ**

តើសហចុងចម្លើយឈ្មោះ [redacted] ចាន់ណារិន និងឈ្មោះ [redacted] រីវ៉ាន់ ពិតជាបានខ្ចីបរិភោគពីធនាគារ [redacted] ដូចមានក្នុងកិច្ចសន្យាខ្ចីបរិភោគ ដែលត្រូវបានធ្វើឡើងកាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ដែរឬទេ?



Scanned with CamScanner

### ៣. ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ

#### ក. ការអះអាងរបស់ដើមចោទ

កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ សហចុងចម្លើយឈ្មោះ [redacted] **ចាន់ណារិន** និងម្តាយឈ្មោះ [redacted] **រីភ៉ន់** បានចុះកិច្ចសន្យាខ្ចីបរិភោគជាមួយ **ធនាគារ** [redacted] ដោយទទួលបានកម្ចីជាប្រាក់ដើមសរុបចំនួន USD ១០.៧០០.០០០ (ដប់លានប្រាំពីររយពាន់ដុល្លារអាមេរិក) ដោយបានកំណត់ឥណទានជាពីរប្រភេទដូចខាងក្រោម៖

**១. ចំពោះឥណទានអាជីវកម្ម** (Fixed Loan) មានប្រាក់ដើមសរុបចំនួន USD ៨.៧០០.០០០ (ប្រាំបីលានប្រាំពីររយពាន់ដុល្លារអាមេរិក) ក្នុងអត្រាការប្រាក់ ៨,៥០% (ប្រាំបីក្បៀសហាសិបភាគរយ) ក្នុង០១ឆ្នាំ និងការប្រាក់ពិន័យចំនួន២៤% (ម្ភៃបួនភាគរយ) ក្នុង០១ឆ្នាំ មានរយៈពេលប្រើប្រាស់កម្ចី១២០ (មួយរយម្ភៃ)ខែ ដោយធ្វើការបង់រំលស់ប្រាក់ដើម បូកនិងការប្រាក់បង់រំលស់ប្រចាំខែមួយៗស្មើៗគ្នា (EMI) រៀងរាល់ខែ ចាប់ពីថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២២ ដល់ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០៣២ ទៅតាមតារាងកាលវិភាគសងប្រាក់របស់ធនាគារ ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២។

**២. ចំពោះឥណទានវិបារូបន៍** (Overdraft Loan) មានប្រាក់ដើមសរុបចំនួន USD ២.០០០.០០០ (ពីរលានដុល្លារអាមេរិក) ក្នុងអត្រាការប្រាក់ ៨,៧៥% (ប្រាំបីក្បៀសចិតសិបប្រាំភាគរយ) ក្នុង០១ឆ្នាំ មានរយៈពេលប្រើប្រាស់កម្ចីចំនួន ១២(ដប់ពីរ)ខែ ដោយធ្វើការបង់ការប្រាក់រៀងរាល់ប្រចាំខែម្តង តាមការប្រើប្រាស់ប្រាក់ដើមជាក់ស្តែង និងបង់ផ្តាច់ប្រាក់ដើម និងការប្រាក់រៀងរាល់១២(ដប់ពីរ)ខែម្តង ហើយការអនុម័តសម្រេចបន្តឥណទាននេះនឹងធ្វើឡើងតាមឆន្ទានុសិទ្ធិដាច់ខាតរបស់ធនាគារ ដោយយោងតាមលិខិតផ្តល់ឥណទាន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២។

ចំពោះរបៀបបង់សងប្រាក់មកធនាគារ សហចុងចម្លើយត្រូវអនុវត្តតាមតារាងកាលវិភាគសងប្រាក់ ដោយសងប្រាក់ដើម ឬការប្រាក់មួយលើកៗ ត្រូវបង់ប្រាក់ដោយផ្ទាល់ ឬកាត់យកដោយស្វ័យប្រវត្តិពីគណនីរបស់ សហចុងចម្លើយដូចដែលមានចែងក្នុងចំណុចទី២ (ការពិពណ៌នាលម្អិតនៃឥណទាន) នៃលិខិតផ្តល់ឥណទាន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២។ ក្រោយពីទទួលបានកម្ចីពីធនាគារព្រីនស៍ ម.ក ទាំង០២ ប្រភេទនេះរួចមក សហចុង-ចម្លើយបានទូទាត់សងប្រាក់ត្រឡប់មកធនាគារវិញ បានតែមួយរយៈពេលខ្លីតែប៉ុណ្ណោះ ហើយបានខកខានមិនបាន បង់ប្រាក់មកធនាគារ ជាបន្តបន្ទាប់តាំងពីបានទទួលឥណទានមក។ ដូច្នេះស្របតាមស្មារតីនៃកិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ និងលិខិតផ្តល់ឥណទាន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២ កូនក្តីរបស់ខ្លួនបានអនុវត្ត សិទ្ធិស្របច្បាប់របស់ខ្លួន ព្រមទាំងបានជូនដំណឹងដល់សហចុងចម្លើយអំពីការតម្លើងការប្រាក់ក្នុងអត្រា១៨% (ដប់ប្រាំបីភាគរយ) ក្នុង០១ឆ្នាំ លើប្រាក់ដើមកម្ចីជាឥណទានអាជីវកម្ម( Fixed Loan) ចំនួន USD ៨.៥៣៨.៥៤៨,៩១ (ប្រាំបីលានប្រាំរយសាមសិបប្រាំបីពាន់ប្រាំរយសែសិបប្រាំបីដុល្លារអាមេរិក ក្បៀសកៅសិបមួយសេន) ដែលសហចុងចម្លើយបានជំពាក់កូនក្តីរបស់ខ្លួន ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌនៃកិច្ច



Scanned with CamScanner

សន្យាខ្ចីបរិភោគ និងលិខិតផ្ដល់ឥណទាន ដែលមានការផ្ដិតស្នាមមេដៃទទួល និងយល់ព្រមពីសហចុងចម្លើយ នៅពេលធ្វើឥណទាន និងកំណត់យ៉ាងច្បាស់នៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌរួមនៃឥណទានត្រង់ប្រការ៧ ស្ដីពីអត្រាការប្រាក់ និងអត្រាការប្រាក់ករណីបំពានលក្ខខណ្ឌថា **"ម្ចាស់បំណុល អាចកែប្រែអត្រាការប្រាក់ ឬអត្រាក្នុងករណីបំពានលក្ខខណ្ឌ នៅគ្រប់ពេលវេលា និងតាមឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនបាច់មានការជូនដំណឹង"** និងត្រង់ប្រការ១៨ ស្ដីពីសិទ្ធិ និងដំណោះស្រាយក្នុងករណីបំពានលក្ខខណ្ឌថា **"ម្ចាស់បំណុលមានសិទ្ធិបង្កើនអត្រាការប្រាក់ក្នុងករណីបំពានលក្ខខណ្ឌ និងកម្រៃសេវា និងការចំណាយផ្សេងទៀតទាក់ទងនឹងឥណទាន"** ដែលបង្កើតដោយធនាគារ និងសហចុងចម្លើយ ដោយមានស្នាមមេដៃរបស់សហចុងចម្លើយ និងត្រាធនាគារត្រឹមត្រូវ ព្រមទាំងមានប្រថាប់ត្រាមេធាវីអមផងដែរ។ មួយវិញទៀត នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ សហចុងចម្លើយ ក៏បានទទួលដំណឹងលើការកែប្រែអត្រាការប្រាក់ទៅ១៨%(ដប់ប្រាំបីភាគរយ) ក្នុង០១ឆ្នាំ ចំពោះឥណទានអាជីវកម្ម(Fixed Loan) និងឥណទានវិបារូបន៍ (Overdraft Loan) ក្នុងករណីមិនមកទូទាត់សងបំណុលតាមការជូនដំណឹងរបស់ធនាគារ[redacted] ផងដែរ។ ទន្ទឹមនឹងនេះ ដើម្បីធានាទទួលរងពីការបំពានលក្ខខណ្ឌនៃកិច្ចសន្យាខ្ចីបរិភោគ សហចុងចម្លើយបានបង្កើត ហ៊ីប៉ូតែកលើអចលនវត្ថុរបស់ខ្លួន ០១កន្លែង តាមរយៈការចុះកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ ចំពោះអចលនវត្ថុ ដី/ផ្ទះ មានទំហំ ២១.៣៨៩ ម$^{២}$ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២១២០១០៣-០៨០៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ដែលមានទីតាំងស្ថិតនៅភូមិស្វាយចេក សង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។ បន្ទាប់ពីបានចុះកិច្ចសន្យាខ្ចីបរិភោគ ដោយអនុវត្តបានមួយរយៈពេលខ្លី សហចុងចម្លើយមិនបានគោរពកាតព្វកិច្ចនៃការបង់ការប្រាក់តាមកិច្ចសន្យាឡើយ ដោយបានខកខានមិនបានបង់ការប្រាក់ និងប្រាក់ដើមមកធនាគារអស់ជាច្រើនខែ ទោះបីជាមានការដាស់តឿនជាច្រើនលើកច្រើនសារ រួចមកហើយក៏សហចុងចម្លើយនៅមិនព្រមចូលខ្លួនមកដោះស្រាយ។ ការបំពានលក្ខខណ្ឌនៃកិច្ចសន្យានេះ បានបញ្ជាក់ពីការអស់លទ្ធភាពការគ្មានឆន្ទៈ និងការគេចវេសពីការទូទាត់សងប្រាក់មក ធនាគារ[redacted]យ៉ាងពិតប្រាកដ។

យោងតាមរបាយការណ៍ស្ដីពីបំណុលចុងក្រោយរបស់ ធនាគារ [redacted] បំណុលរបស់សហចុងចម្លើយឈ្មោះ [redacted] ចាន់ណារិន និងម្ដាយឈ្មោះ [redacted] រីវ៉ាន់ នៅជំពាក់ធនាគារនូវប្រាក់សដើមសរុបចំនួន USD ១០.៥៨៣.១៨៨,៤៥ (ដប់លានប្រាំរយប៉ែតសិបបីពាន់មួយរយប៉ែតសិបប្រាំបីដុល្លារអាមេរិកកៀសសែសិបប្រាំសេន) រួមទាំងការប្រាក់ គិតចាប់ពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ និងការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣។

**ខ. ការអះអាងរបស់សហចុងចម្លើយ**

សុំបដិសេធពាក្យបណ្ដឹង ក៏ដូចជាការទាមទារក្នុងពាក្យបណ្ដឹងចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២៣ ដោយសារកូនក្ដីរបស់ខ្លួន ឈ្មោះ [redacted] រីវ៉ាន់ គាត់បានអះអាងថា គាត់មិនបានខ្ចីប្រាក់ពីធនាគារដូចមាននៅក្នុងពាក្យបណ្ដឹងឡើយ ហើយក៏មិនដែលធ្លាប់បានទទួលប្រាក់ពីធនាគារនោះដែរ។ កន្លងមកកូនប្រុសរបស់គាត់



Scanned with CamScanner

ឈ្មោះ [redacted] ចាន់ណារិន ធ្លាប់បានហៅគាត់ទៅធនាគារ ដើម្បីផ្តិតមេដៃលើឯកសារមួយចំនួនដោយគាត់ប្រាប់ថា ឈ្មោះ [redacted] ចាន់ណារិន ត្រូវការខ្ចីប្រាក់ពីធនាគារ តែខ្ចីចំនួនប៉ុន្មាននោះកូនក្តីខ្លួនពុំបានដឹងឡើយ។ ព្រោះកូនក្តីរបស់ខ្ញុំ គាត់មិនបានដឹងពីបញ្ហាខ្ចីលុយនេះទេ។ កូនប្រុសរបស់គាត់ឈ្មោះ [redacted] ចាន់ណារិន ធ្លាប់ហៅគាត់ទៅធនាគារដើម្បីផ្តិតមេដៃ ដឹងឮក្នុងនាមជាសាក្សីតែប៉ុណ្ណោះ មិនមែនជាអ្នកខ្ចីទេ។ ចំពោះខ្លឹមសារក្នុងឯកសាររបស់ធនាគារ កូនក្តីរបស់ខ្ញុំមិនបានដឹងឮឡើយ។ម្យ៉ាងវិញទៀតចំពោះការខ្ចីបរិភោគនេះ កូនក្តីរបស់ខ្ញុំ មិនបានទទួលលុយទេ ដោយពុំមានកិច្ចសន្យាទទួលប្រាក់ ណាមួយកូនក្តីរបស់ខ្ញុំមានអាយុ៦៣ឆ្នាំ ឲ្យខ្ចីនេះមានលទ្ធភាពឬអត់ទេ ព្រោះគាត់អត់មានចំណូលទេ តើធនាគារឲ្យខ្ចីទេ ចំណែកឯកសារទាំងអស់របស់ធនាគារគឺមានតែកិច្ចសន្យាខ្ចីបរិភោគ តែប៉ុណ្ណោះ ដែលមានផ្តិតមេដៃកូនក្តីរបស់ខ្ញុំ តែមិនដឹងពីអត្ថន័យខ្លឹមសារឡើយ ហើយក៏មិនបានទទួលលុយដែរ ពុំមានឯកសារណាមួយបញ្ជាក់ថា កូនក្តីរបស់ខ្ញុំ បានខ្ចីប្រាក់ទេ ហើយអ្នកណាដែលខ្ចីពិតប្រាកដមានតែធនាគារទេ ទើបដឹង។ ដូច្នេះ សុំបដិសេធពាក្យបណ្តឹងទាំងស្រុង។

## សំអាងហេតុ

### ក. ការវិនិច្ឆ័យអំពីចំណុចវិវាទ

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានបង្ហាញថា សហចុងចម្លើយឈ្មោះ [redacted] ចាន់ណារិន និងម្តាយឈ្មោះ [redacted] រីវ៉ាន់ បានចុះកិច្ចសន្យាខ្ចីបរិភោគជាមួយ **ធនាគារ** [redacted] ដោយទទួលបានកម្ចីជាប្រាក់ដើមសរុបចំនួន USD ១០.៧០០.០០០ (ដប់លានប្រាំពីររយពាន់ដុល្លារអាមេរិក) ដោយបានកំណត់ឥណទានជា ០២ប្រភេទ គឺ **ឥណទានអាជីវកម្ម** (Fixed Loan) មានប្រាក់ដើមសរុបចំនួន USD ៨.៧០០.០០០ (ប្រាំបីលានប្រាំពីររយពាន់ដុល្លារអាមេរិក) និង **ឥណទានវិបារូបន៍** (Overdraft Loan) មានប្រាក់ដើមសរុបចំនួន USD ២.០០០.០០០ (ពីរលានដុល្លារអាមេរិក)។ ចំណែកអ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយឈ្មោះ [redacted] រីវ៉ាន់ បានបង្ហាញថា ចុងចម្លើយមិនបានខ្ចីប្រាក់ពីធនាគារដូចមាននៅក្នុងពាក្យបណ្តឹងឡើយ ហើយក៏មិនដែលធ្លាប់បានទទួលប្រាក់ពីធនាគារនោះដែរ ប៉ុន្តែចុងចម្លើយ បានទទួលស្គាល់ថា ធ្លាប់បានទៅធនាគារដើម្បីផ្តិតមេដៃលើឯកសារមួយចំនួន ព្រោះចុងចម្លើយឈ្មោះ [redacted] ចាន់ណារិន ត្រូវការខ្ចីប្រាក់ពីធនាគារ។ ចំណុចនេះឃើញថា បើផ្អែកតាមសេចក្តីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិរបស់ដើមចោទនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ បានបញ្ជាក់ថា គ្រប់ឯកសារ ទាំងអស់ដែលពាក់ព័ន្ធនឹងឯកសារឥណទានបានធ្វើឡើង នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ រវាង **ធនាគារ**[redacted] និងសហចុងចម្លើយឈ្មោះ [redacted] **ចាន់ណារិន** និងម្តាយឈ្មោះ [redacted] **រីវ៉ាន់** គឺជាការព្រមព្រៀងដោយត្រឹមត្រូវទៅតាមច្បាប់ ដោយគ្មានការបង្ខិតបង្ខំពីសំណាក់ភាគីណាមួយឡើយ ហើយភាគីសហចុងចម្លើយក៏សុទ្ធតែជានីតិជន ព្រមទាំងមានទូវសម្បទាគ្រប់គ្រាន់ក្នុងការបង្ហាញ ឆន្ទៈផងដែរ។ មួយវិញទៀត រាល់ឯកសារពាក់ព័ន្ធនឹងឥណទានទាំងអស់ ដែលធ្វើឡើងរវាង **ធនាគារ** និងសហចុងចម្លើយ គឺសុទ្ធតែមានការប្រថាប់ត្រាបញ្ជាក់ដោយមេធាវី ដែលបានបញ្ជាក់ថា គូភាគីបានផ្តិតមេដៃនៅចំពោះមុខមេធាវី។ ទន្ទឹមនឹងនោះ តាមការ

ពិនិត្យ ភស្តុតាងឯកសារ កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ លិខិតផ្តល់ឥណទាន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ បង្ហាញថា សហចុងចម្លើយពិតជាបានចុះកិច្ចសន្យាខ្ចីបរិភោគ ជាមួយដើមចោទ។

**ខ. ការវិនិច្ឆ័យអំពីការទាមទារ**

១. ក្នុងរឿងក្តីនេះ ដើមចោទទាមទារប្រាក់ដើមសរុបចំនួន ១០.៥៨៣.១៨៨,៤៥ (ដប់លានប្រាំរយប៉ែតសិបបីពាន់ មួយរយប៉ែតសិបប្រាំបី ដុល្លារអាមេរិក សែសិបប្រាំសេន) ដោយផ្អែកតាម កិច្ចសន្យាខ្ចីបរិភោគ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ លិខិតផ្តល់ឥណទាន ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២២ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២។ម្យ៉ាងទៀត បើផ្អែកតាមសំអាងហេតុ ការវិនិច្ឆ័យលើចំណុចវិវាទ ឃើញថា តុលាការទទួលស្គាល់សហចុងចម្លើយពិតជាបានចុះកិច្ចសន្យាខ្ចីបរិភោគ ជាមួយដើមចោទប្រាកដមែន ហើយតាមការបញ្ជាក់របស់អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ ឃើញថា ក្រោយបានចុះកិច្ចសន្យាខ្ចីបរិភោគលើឥណទានទាំង ០២ ប្រភេទនេះ សហចុងចម្លើយបានអនុវត្តកាតព្វកិច្ច បង់ប្រាក់សងត្រឡប់មកធនាគារវិញ បានតែមួយរយៈពេលខ្លីតែប៉ុណ្ណោះ ហើយនៅជំពាក់ប្រាក់ដើមជាក់ស្តែងចំនួន USD ១០.៥៨៣.១៨៨,៤៥ (ដប់លានប្រាំរយប៉ែតសិបបីពាន់ មួយរយប៉ែតសិបប្រាំបី ដុល្លារអាមេរិក សែសិបប្រាំសេន)។ ដូច្នេះតុលាការយល់ឃើញថា មានភស្តុតាងជាក់ស្តែងដើម្បីទទួលស្គាល់ថា សហចុងចម្លើយនៅជំពាក់ប្រាក់ដើមចោទចំនួន USD ១០.៥៨៣.១៨៨,៤៥ (ដប់លានប្រាំរយប៉ែតសិបបីពាន់ មួយរយប៉ែតសិបប្រាំបី ដុល្លារអាមេរិក សែសិបប្រាំសេន)។

២. ដើមចោទទាមទារ ការប្រាក់ទៅតាមឥណទានពីរប្រភេទគឺ ឥណទានអាជីវកម្ម (Fixed Loan) ក្នុងអត្រាការប្រាក់ ៨,៥០% (ប្រាំបីក្បៀសហាសិបភាគរយ) ក្នុង០១ឆ្នាំ គិតចាប់ពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ និងក្នុងអត្រាការប្រាក់ ១៨% (ដប់ប្រាំបីភាគរយ) ក្នុង០១ឆ្នាំ គិតចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់សងគ្រប់ចំនួន លើប្រាក់ដើមចំនួន USD ៨.៥៣៨.៥៤៨,៩១ (ប្រាំបីលាន ប្រាំរយសាមសិបប្រាំបីពាន់ ប្រាំរយសែសិបប្រាំបី ដុល្លារអាមេរិក កៅសិបមួយសេន) និងឥណទានវិបារូបន៍ (Overdraft Loan) ក្នុងអត្រាការប្រាក់ ៨,៧៥% (ប្រាំបីក្បៀសចិតសិបប្រាំ ភាគរយ) ក្នុង០១ឆ្នាំ គិតចាប់ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ និងក្នុងអត្រាការប្រាក់ ១៨% (ដប់ប្រាំបីភាគរយ) ក្នុង០១ឆ្នាំ គិតចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់សងគ្រប់ចំនួនលើប្រាក់ដើមចំនួន USD ២.០៤៤.៦៣៩,៥៤ (ពីរលានសែសិបបួនពាន់ប្រាំមួយរយសាមសិបប្រាំបួន ដុល្លារអាមេរិក ហាសិបបួនសេន)។ អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានអះអាងថា ភាគីទាំងសងខាងបានកំណត់យកអត្រាការប្រាក់ ក្នុងអត្រាការប្រាក់ ៨,៥០% (ប្រាំបីក្បៀសហាសិបភាគរយ) ក្នុង០១ឆ្នាំ **ចំពោះឥណទានអាជីវកម្ម** (Fixed Loan) និងក្នុងអត្រាការប្រាក់ ៨,៧៥% (ប្រាំបីក្បៀសចិតសិបប្រាំភាគរយ) ក្នុង០១ឆ្នាំ **ចំពោះឥណទានវិបារូបន៍** (Overdraft Loan) ដែលមានចែងត្រង់ប្រការ **២** នៃកិច្ចសន្យាខ្ចីបរិភោគ ព្រមទាំងបានចែង



Scanned with CamScanner

លំអិតនៅក្នុងប្រការ **២** នៃលិខិតផ្តល់ឥណទាន ដែលចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២២ និង **ធនាគារ** បានអនុវត្តសិទ្ធិស្របច្បាប់របស់ខ្លួនក្នុងការតម្លើងអត្រាការប្រាក់ទៅចំនួន **១៨%** (ដប់ប្រាំបីភាគរយ) ក្នុង០១ឆ្នាំ លើឥណទានទាំង **០២** ប្រភេទនេះ ដោយស្របតាមបញ្ញត្តិ និងលក្ខខណ្ឌ នៃកិច្ចសន្យាខ្ចីបរិភោគ និងលិខិតផ្តល់ឥណទាន ដែលមានលិខិតស្នាមមេដៃទទួល និងយល់ព្រមពីសហចុងចម្លើយ ផងដែរ នៅពេលធ្វើឥណទាន និងកំណត់យ៉ាងច្បាស់នៅក្នុងបញ្ញត្តិ និងលក្ខខណ្ឌរួមនៃឥណទាន ត្រង់ប្រការ ៧ ស្តីពី **អត្រាការប្រាក់ និងអត្រាការប្រាក់ករណីបំពានលក្ខខណ្ឌ** ថា “ **ម្ចាស់បំណុល អាចកែប្រែអត្រាការប្រាក់ ឬ អត្រាក្នុងករណីបំពានលក្ខខណ្ឌនៅគ្រប់ពេលវេលា និងតាមឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនបាច់មានការជូនដំណឹង**” និងត្រង់ប្រការ ១៨ ស្តីពី **សិទ្ធិ និងដំណោះស្រាយក្នុងករណីបំពានលក្ខខណ្ឌ** ថា “**ម្ចាស់បំណុលមានសិទ្ធិបង្កើន អត្រាការប្រាក់ក្នុងករណីបំពានលក្ខខណ្ឌ និងកម្រៃសេវា និងការចំណាយផ្សេងទៀតទាក់ទងនឹង ឥណទាន**” ដែលបង្កើតដោយធនាគារ និងសហចុងចម្លើយ ដោយមានស្នាមមេដៃរបស់សហចុងចម្លើយ និងត្រាធនាគារត្រឹមត្រូវ ដោយមានទាំងប្រថាប់ត្រាមេធាវីបានឃើញគូភាគីផ្តិតមេដៃ ផងដែរ។ មួយវិញទៀត នាថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ សហចុងចម្លើយ ក៏បានទទួលដំណឹងលើការកែប្រែអត្រាការប្រាក់ទៅ **១៨%** (ដប់ប្រាំបីភាគរយ) ក្នុង**០១ឆ្នាំ** ចំពោះ**ឥណទានអាជីវកម្ម (Fixed Loan)** និង **ឥណទានវិបារូបន៍** (Overdraft Loan) ក្នុងករណីមិនមកទូទាត់សងបំណុលតាមការជូនដំណឹងរបស់ធនាគារផងដែរ។

ការព្រមព្រៀងកំណត់យកអត្រាការប្រាក់រវាង **ធនាគារ** និងសហចុងចម្លើយនេះ គឺមានលក្ខណៈត្រឹមត្រូវតាមមាត្រា ៥៨៤ កថាខណ្ឌទី១ (អត្រាការប្រាក់ដែលកំណត់ដោយច្បាប់ និងអត្រាការប្រាក់ក្នុងកិច្ចសន្យា) នៃក្រមរដ្ឋប្បវេណី ព្រមទាំងមានលក្ខណៈស្របតាមប្រកាសស្តីពី អត្រាការប្រាក់ដែលត្រូវបានកម្រិតលេខ **១២៨ កយ.ប្រក/១១** ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ និងប្រកាសស្តីពីការកំណត់ពិដានអត្រាការប្រាក់ឥណទានលេខ៖ **ធ៧ ០១៧ ១០៩ ប្រក** ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧ របស់ធនាគារជាតិ នៃកម្ពុជាផងដែរ។ ដោយផ្អែកតាមមាត្រា ៣៩៩ (បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់) នៃក្រមរដ្ឋប្បវេណី ហើយបច្ចុប្បន្ននេះសហចុងចម្លើយនៅប្រើប្រាស់សាច់ប្រាក់ដែលបានមកពីកម្ចីរបស់ធនាគារ។ ដូច្នេះ មានភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា សហចុងចម្លើយត្រូវបង់ជូន ធនាគារ នូវអត្រាការប្រាក់តាមការព្រមព្រៀងនៅក្នុងកិច្ចសន្យាខាងលើនេះ។

៣. **ដើមចោទទាមទារ ប្រាក់ពិន័យ និងការប្រាក់ដែលខកខានមិនបានបង់ ក្នុងអត្រាការប្រាក់** ២៤% (ម្ភៃបួនភាគរយ) ក្នុង០១ឆ្នាំ គិតចាប់ពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់សងគ្រប់ចំនួន ចំពោះ **ឥណទានអាជីវកម្ម (Fixed Loan)** លើប្រាក់ដើមចំនួន USD ៨.៥៣៨.៥៤៨,៩១ (ប្រាំបីលានប្រាំរយសាមសិបប្រាំបីពាន់ប្រាំរយសែសិបប្រាំបី ដុល្លារអាមេរិក កៀសកៅសិបមួយសេន) និងក្នុងអត្រាការប្រាក់ ២៤% (ម្ភៃបួនភាគរយ) ក្នុង០១ឆ្នាំ គិតចាប់ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទូទាត់សងគ្រប់ចំនួន ចំពោះ**ឥណទានវិបារូបន៍** (Overdraft Loan) លើប្រាក់ដើមចំនួន USD ២.០៤៤.៦៣៩,៥៤ (ពីរលាន សែសិបបួនពាន់ ប្រាំមួយរយសាមសិបប្រាំបួន ដុល្លារអាមេរិក កៀសហាសិបបួនសេន)។ អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានលើក



Scanned with CamScanner

ឡើងថា ចំពោះសំណងនៃការខូចខាត(ការប្រាក់ពិន័យ) ដោយសារតែសហចុងចម្លើយជាអ្នកបំពានកាតព្វកិច្ចមិនបានមកបង់ប្រាក់តាមកាលកំណត់ ដោយបានចែងនៅក្នុងកិច្ចសន្យាខ្ចីបរិភោគខាងលើ និងផ្អែកតាមមាត្រា ៣៩៩ (បញ្ញត្តិពិសេសអំពីកាតព្វកិច្ចជាប្រាក់) និងមាត្រា ៤០០ (ទសន្ស: អំពីការខូចខាត) នៃក្រមរដ្ឋប្បវេណី ហើយបច្ចុប្បន្ននេះ សហចុងចម្លើយ នៅប្រើប្រាស់សាច់ប្រាក់ដែលបានមកពី កម្ចីរបស់ ធនាគារ នៅឡើយ។ ដូច្នេះមានភស្តុងគ្រប់គ្រាន់ដើម្បីបញ្ជាក់ថា សហចុងចម្លើយត្រូវបង់ជូន ធនាគារ តាមការព្រមព្រៀងនៅក្នុងកិច្ចសន្យាខាងលើនេះ។

៤. ដើមចោទទាមទារឱ្យសហចុងចម្លើយបង់ថ្លៃសេវាកម្មផ្នែកច្បាប់ សំណងការខូចខាត និងការខាតបង់ពេលវេលា ចំនួន USD ១៥០.០០០ (មួយរយហាសិបពាន់ ដុល្លារអាមេរិក)។ អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានអះអាងថា ដោយសារសហចុងចម្លើយ មិនបានអនុវត្តកាតព្វកិច្ចពេញលេញតាមកិច្ចសន្យាដែលបានព្រមព្រៀងគ្នា ហើយការបំពានកាតព្វកិច្ចនេះ ទៀតសោត ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ របស់ធនាគារយ៉ាងខ្លាំងដែលជាហេតុ ធនាគារ ចាំបាច់ត្រូវចំណាយ លើការដំណើរការនីតិវិធីតុលាការ ជាមួយនឹងសហចុងចម្លើយស្របពេលដែល ធនាគារ អាចបំពេញអាជីវកម្មផ្សេង ទៀត បានប្រសិនបើសហចុងចម្លើយ បានអនុវត្តកាតព្វកិច្ចតាមកាលកំណត់ ហើយសហចុងចម្លើយក៏បានយល់ ព្រមសុខចិត្តទទួលខុសត្រូវ ករណីដែលមានវិវាទកើតឡើងដោយសារកំហុសខ្លួន ផងដែរ ដែលមានចែងនៅក្នុង ប្រការ ១៤ នៃឧបសម្ព័ន្ធ កិច្ចសន្យាបង្កើតហ៊ីប៉ូតែក នៅថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០២២ ព្រមទាំងស្របតាមមាត្រា ៤០៤ (គោលការណ៍នៃការសងការខូចខាតជាប្រាក់) នៃក្រមរដ្ឋប្បវេណី។

៥. យល់ឃើញថា ការទាមទារចំណុចទី១ ទី២ និងទី៣ របស់ដើមចោទ មានមូលហេតុត្រឹមត្រូវ។

៦. យល់ឃើញថា ការទាមទារចំណុចទី៤ ឃើញថា ការទាមទារសេវាកម្មផ្នែកច្បាប់ សំណងការខូចខាត និងការខាតបង់ពេលវេលាចំនួន USD ១៥០.០០០ (មួយរយហាសិបពាន់ ដុល្លារអាមេរិក) ដើមចោទពុំបានបង្ហាញអង្គហេតុ និងភស្តុតាងឱ្យបានច្បាស់លាស់អំពីការខូចខាតរបស់ខ្លួនឡើយ ហេតុនេះគប្បីតុលាការពិចារណា អំពីចំនួនដែលសមរម្យដោយពិចារណាទៅលើការខកខានរហូតដល់កាតព្វកិច្ចត្រូវបានអនុវត្ត ។

៧. យល់ឃើញថា ការទាមទារ ឱ្យមានការប្រកាសឱ្យអនុវត្តសាលក្រមជាបណ្តោះអាសន្នត្រង់ចំណុចទី១ ទី២ ទី៣ និងទី៤ តុលាការពិនិត្យឃើញថា ការទាមទារចំណុចទី១ របស់ដើមចោទ គឺជាការទាមទារជាប្រាក់ ហើយតុលាការទទួលស្គាល់ថាមានភាពចាំបាច់ក្នុងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដោយផ្អែកតាមមាត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្រៅពីនេះឃើញថា ពុំមានភាពចាំបាច់ឡើយ។

៨. យល់ឃើញថា ប្រាក់ប្រដាប់ក្តីដែលដើមចោទបានបង់ ជាបន្ទុករបស់ភាគីសហចុងចម្លើយ ផ្អែកតាមមាត្រា៦៤ និងមាត្រា៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ហេតុដូច្នេះតុលាការធ្វើការវិនិច្ឆ័យ និងសម្រេចដូចខាងក្រោម៖



Scanned with CamScanner

## សេចក្ដីសម្រេចបញ្ចប់

១. បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ចាន់ណារិន និងឈ្មោះ [redacted] រីរ៉ាន់ សងប្រាក់ដើមសរុបចំនួន USD ១០.៥៨៣.១៨៨,៤៥ (ដប់លានប្រាំរយប៉ែតសិបបីពាន់ មួយរយប៉ែតសិបប្រាំបី ដុល្លារអាមេរិក ក្បៀសសែសិបប្រាំសេន) ទៅឱ្យដើមចោទ។

២. បង្គាប់ឱ្យសហចុងចម្លើយសងការប្រាក់៖

២.១. ចំពោះឥណទានអាជីវកម្ម (Fixed Loan) ក្នុងអត្រាការប្រាក់ ៨,៥០% (ប្រាំបីក្បៀសហាសិបភាគរយ) ក្នុង០១ឆ្នាំ លើប្រាក់ដើមចំនួន USD ៨.៥៣៨.៥៤៨,៩១ (ប្រាំបីលាន ប្រាំរយសាមសិបប្រាំបីពាន់ ប្រាំរយសែសិបប្រាំបី ដុល្លារអាមេរិក ក្បៀសកៅសិបមួយសេន) គិតចាប់ពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ និងក្នុងអត្រាការប្រាក់ ១៨% (ដប់ប្រាំបីភាគរយ) ក្នុង០១ឆ្នាំ លើប្រាក់ដើមចំនួន USD ៨.៥៣៨.៥៤៨,៩១ (ប្រាំបីលាន ប្រាំរយសាមសិបប្រាំបីពាន់ ប្រាំរយសែសិបប្រាំបី ដុល្លារអាមេរិក ក្បៀសកៅសិបមួយសេន) គិតចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ រហូតដល់កាលបរិច្ឆេទទូទាត់សងគ្រប់ចំនួន ទៅឱ្យដើមចោទ។

២.២. ចំពោះឥណទានវិបារូបន៍ (Overdraft Loan) ក្នុងអត្រាការប្រាក់ ៨,៧៥% (ប្រាំបីក្បៀសចិតសិបប្រាំ ភាគរយ) ក្នុង០១ឆ្នាំ លើប្រាក់ដើមចំនួន USD ២.០៤៤.៦៣៩,៥៤ (ពីរលានសែសិបបួនពាន់ប្រាំមួយរយសាមសិបប្រាំបួន ដុល្លារអាមេរិក ក្បៀសហាសិបបួនសេន) គិតចាប់ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ និងក្នុងអត្រាការប្រាក់ ១៨% (ដប់ប្រាំបីភាគរយ) ក្នុង០១ឆ្នាំ លើប្រាក់ដើមចំនួន USD ២.០៤៤.៦៣៩,៥៤ (ពីរលានសែសិបបួនពាន់ប្រាំមួយរយសាមសិបប្រាំបួន ដុល្លារអាមេរិក ក្បៀសហាសិបបួនសេន) គិតចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ រហូតដល់កាលបរិច្ឆេទទូទាត់សងគ្រប់ចំនួន ទៅឱ្យដើមចោទ។

៣. បង្គាប់ឱ្យសហចុងចម្លើយបង់ការប្រាក់ពិន័យ៖

៣.១. ចំពោះឥណទានអាជីវកម្ម (Fixed Loan) ក្នុងអត្រាការប្រាក់ ២៤% (ម្ភៃបួនភាគរយ) ក្នុង០១ឆ្នាំ នៃប្រាក់ដើមចំនួន USD ៨.៥៣៨.៥៤៨,៩១ (ប្រាំបីលានប្រាំរយសាមសិបប្រាំបីពាន់ប្រាំរយសែសិបប្រាំបី ដុល្លារអាមេរិក ក្បៀសកៅសិបមួយសេន) និងការប្រាក់ដែលខកខានមិនបានបង់ គិតចាប់ពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៣ រហូតដល់កាលបរិច្ឆេទទូទាត់សងគ្រប់ចំនួន ទៅឱ្យដើមចោទ។

៣.២. ចំពោះឥណទានវិបារូបន៍ (Overdraft Loan) ក្នុងអត្រាការប្រាក់ ២៤% (ម្ភៃបួនភាគរយ) ក្នុង០១ឆ្នាំ នៃប្រាក់ដើមចំនួន USD ២.០៤៤.៦៣៩,៥៤ (ពីរលាន សែសិបបួនពាន់ ប្រាំមួយរយសាមសិបប្រាំបួន ដុល្លារអាមេរិក ក្បៀសហាសិបបួនសេន) និងការប្រាក់ដែលខកខានមិនបានបង់ គិតចាប់ពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣ រហូតដល់កាលបរិច្ឆេទទូទាត់សងគ្រប់ចំនួន ទៅឱ្យដើមចោទ។

៤. បង្គាប់ឱ្យសហចុងចម្លើយបង់ថ្លៃសេវាកម្មផ្នែកច្បាប់ សំណងការខូចខាត និងការខាតបង់ពេលវេលាចំនួន ២០.០០០.០០០ (ម្ភៃលាន)រៀល។ ការទាមទារលើសពីនេះត្រូវច្រានចោល។



Scanned with CamScanner

៥. ប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នត្រង់សេចក្តីសម្រេចចំណុចទី១ នៃសាលក្រមនេះ។

៦. ប្រាក់ប្រដាប់ក្តី គឺជាបន្ទុករបស់សហចុងចម្លើយឈ្មោះ [redacted] ចាន់ណារិន និងឈ្មោះ [redacted] រីរ៉ាន់។

សាលក្រមនេះត្រូវបានប្រកាសនៅក្នុងសវនាការជាសាធារណៈ នៅវេលាម៉ោង៣ និង០០នាទី រសៀល នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣។

ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

ថ្ងៃសុក្រ ០១កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ពោធិ៍សាត់ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣

**ចៅក្រម**

**ហត្ថលេខា និងត្រា៖** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ០១រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

ពោធិ៍សាត់ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០២៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ចៅក្រម

[redacted]